Australian Government

ParentsNext

# Participation Plan (ផែនការចូលរួម)

ខ្ញុំយល់ស្របថាការណាត់ជួប និងសកម្មភាពទាំងឡាយដែលមានចែងក្នុងផែនការនេះ នឹងជួយខ្ញុំឱ្យសម្រេចគោលដៅការងារនាពេលអនាគតរបស់ខ្ញុំ។

ខ្ញុំយល់ដឹងថា Participation Plan របស់ខ្ញុំ រួមមានសកម្មភាពដែលខានមិនបានដែលខ្ញុំត្រូវធ្វើ និងការណាត់ជួបដែលខានមិនបានដែលខ្ញុំត្រូវចូលរួម ហើយថាវាចាប់ផ្តើមពីថ្ងៃដែលខ្ញុំចុះហត្ថលេខា។

ខ្ញុំដឹងថា ប្រសិនបើខ្ញុំមិនអាចចូលរួមក្នុងការណាត់ជួប ឬសកម្មភាពណាមួយទេនោះ ខ្ញុំត្រូវតែទាក់ទងអ្នកផ្តល់សេវាកម្ម ParentsNext របស់ខ្ញុំ មុនពេលណាត់ជួប ឬសកម្មភាពត្រូវបានគ្រោងឡើង។ ខ្ញុំយល់ដឹងថាប្រសិនបើខ្ញុំមិនគោរពតាមសកម្មភាពដែលខានមិនបាន និងចូលរួមក្នុងការណាត់ជួបដែលខានមិនបានប្រាក់ឧបត្ថម្ភលើប្រាក់ចំណូលរបស់ខ្ញុំអាចត្រូវបាន ផ្អាក។

ខ្ញុំយល់ដឹងថា ខ្ញុំអាចស្នើសុំឱ្យមានការពិនិត្យឡើងវិញនូវ Participation Plan របស់ខ្ញុំ នៅពេលណាក៏បាន ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរណាមួយនៅក្នុងកាលៈទេសៈរបស់ខ្ញុំ។

**គ្រប់ការឆ្លើយតបត្រូវផ្តល់ជាភាសាអង់គ្លេស**

**ឈ្មោះ៖**

**JSID:** **CRN:**

---

**គោលដៅ -** ទាំងនេះគឺជាគោលដៅការងាររបស់ខ្ញុំ។

**ការណាត់ជួប និងសកម្មភាពនានា -**

ការណាត់ជួប និងសកម្មភាពនានានៅក្នុងផែនការនេះ នឹងជួយឱ្យខ្ញុំឈានដល់គោលដៅរបស់ខ្ញុំ។

| | |
|---|---|
| **ឈ្មោះ៖** | **ព័ត៌មានលម្អិតរបស់អ្នកផ្តល់សេវាកម្ម៖**<br>អ្នកផ្តល់សេវាកម្ម ParentsNext |
| **ហត្ថលេខា៖**<br><br>**កាលបរិច្ឆេទ៖** | **ហត្ថលេខា៖**<br><br>**កាលបរិច្ឆេទ៖** |

# ព័ត៌មានដែលអ្នកចាំបាច់ត្រូវដឹង

## អំពី Participation Plan របស់អ្នក

ក្រោមច្បាប់សន្តិសុខសង្គម មាតាបិតាដែលត្រូវបានតម្រូវឱ្យចូលរួមក្នុង ParentsNext ជាទូទៅត្រូវចូលក្នុង Participation Plan ដើម្បីជួយពួកគេរៀបចំផែនការ និងប្រុងប្រៀបសម្រាប់ការងារ។ Participation Plan នេះ គឺជា Employment Pathway Plan (ផែនការមាគ៌ាទៅកាន់ការងារ) សម្រាប់គោលបំណងនៃ *Social Security Act 1991 (ច្បាប់សន្តិសុខសង្គម ឆ្នាំ១៩៩១)*។

Participation Plan របស់អ្នក ត្រូវបានរៀបចំតាមតម្រូវការជាលក្ខណៈបុគ្គលរបស់អ្នក ហើយរួមមានសកម្មភាព និងការណាត់ជួបនានាដែលអ្នកបានយល់ព្រមអនុវត្ត ដើម្បីបំពេញតាមតម្រូវការកាតព្វកិច្ចរបស់អ្នក ហើយក៏ចែងពីអ្វីដែលអ្នកបានយល់ព្រមធ្វើ ដើម្បីសម្រេចគោលដៅការងារនាពេលអនាគតរបស់អ្នក។

Participation Plan របស់អ្នក ចាប់ផ្តើមពីថ្ងៃដែលអ្នកចុះហត្ថលេខាលើវា ឬយល់ព្រមនៅតាមអនឡាញ។

## តើខ្ញុំគួរធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំមិនអាចធ្វើអ្វីតាមដែលខ្ញុំបានយល់ព្រម?

ប្រសិនបើអ្នកមិនអាចចូលរួមក្នុងការណាត់ជួប ឬចូលរួមសកម្មភាពណាមួយ ដោយហេតុផលណាមួយទេ អ្នកត្រូវតែជូនដំណឹងទៅអ្នកផ្តល់សេវាកម្មរបស់អ្នក (ឬ Services Australia ប្រសិនបើអ្នកមិនមានអ្នកផ្តល់សេវាកម្មណាមួយទេ)។ អ្នកត្រូវតែធ្វើដូចនេះមុនពេលណាត់ជួប ឬសកម្មភាព។ ប្រសិនបើអ្នកមិនជូនដំណឹងដល់ពួកគេ ហើយអ្នកខកខានមិនបានចូលរួមក្នុងការណាត់ជួប ឬសកម្មភាពណាមួយទេ ប្រាក់ឧបត្ថម្ភលើប្រាក់ចំណូលរបស់អ្នកនឹងត្រូវបានផ្អាក ហើយអ្នកអាចនឹងទទួលរងនូវការបាត់បង់គុណសម្បត្តិ។

ដូចគ្នានេះផងដែរ ប្រសិនបើអ្នកបំពេញសកម្មភាពមិនសមរម្យនៅពេលណាត់ជួប ឬសកម្មភាពណាមួយ ឬមិនបំពេញតាមតម្រូវការផ្សេងទៀត ប្រាក់ឧបត្ថម្ភលើប្រាក់ចំណូលរបស់អ្នកនឹងត្រូវបានផ្អាក ហើយអ្នកអាចនឹងទទួលរងនូវការបាត់បង់គុណសម្បត្តិ។

ប្រសិនបើអ្នកនៅតែបន្តមិនបំពេញតាមតម្រូវការរបស់អ្នក អ្នកនឹងមានបទសម្ភាសន៍ជាមួយអ្នកផ្តល់សេវាកម្មរបស់អ្នក (បន្ទាប់ពីការបាត់បង់គុណសម្បត្តិចំនួនបី ក្នុងរយៈពេលប្រាំមួយខែ) ឬការវាយតម្លៃជាមួយសេវាកម្ម Services Australia (បន្ទាប់ពីការបាត់បង់គុណសម្បត្តិចំនួនប្រាំ ក្នុងរយៈពេលប្រាំមួយខែ) ដើម្បីពិភាក្សាពីតម្រូវការរបស់អ្នកហើយហេតុអ្វីបានជាអ្នកមិនបានបំពេញតម្រូវការទាំងនោះ។

ប្រសិនបើមិនមានហេតុផលល្អ ពីមូលហេតុបានជាអ្នកមិនបំពេញតាមតម្រូវការរបស់អ្នក ហើយអ្នកនៅតែបន្តមិនបំពេញតាមតម្រូវការរបស់អ្នក ប្រាក់ឧបត្ថម្ភលើប្រាក់ចំណូលរបស់អ្នកនឹងត្រូវកាត់បន្ថយ ឬលុបចោល។ ប្រសិនបើប្រាក់ឧបត្ថម្ភរបស់អ្នកត្រូវបានលុបចោល អ្នកនឹងមិនទទួលបានប្រាក់នេះរយៈពេលបួនសប្តាហ៍ ហើយអ្នកនឹងត្រូវដាក់ពាក្យសុំម្តងទៀតសម្រាប់ប្រាក់ឧបត្ថម្ភរបស់អ្នក។

ប្រសិនបើមានហេតុផលល្អ ពីមូលហេតុបានជាអ្នកមិនអាចចូលរួមការណាត់ជួប ចូលរួមសកម្មភាព ឬអនុលោមតាមតម្រូវការផ្សេងទៀតនៅក្នុង Participation Plan របស់អ្នក អ្នកត្រូវតែពិភាក្សាអំពីបញ្ហាទាំងនេះជាមួយអ្នកផ្តល់សេវាកម្មរបស់អ្នក (ឬ Services Australia ប្រសិនបើអ្នកមិនមានអ្នកផ្តល់សេវាកម្មណាមួយទេ)។

## តើមានអ្វីកើតឡើងប្រសិនបើអ្នកទទួលបានប្រាក់សម្រាប់ការងារខ្លះ?

អ្នកត្រូវតែប្រាប់សេវាកម្ម Services Australia អំពីប្រាក់ ចំណូលណាមួយដែលអ្នក ឬដៃគូរបស់អ្នកបានទទួលពីការងារដែលមានប្រាក់ឈ្នួលក្នុងពីរសប្តាហ៍ដូចគ្នាដែលអ្នកបានធ្វើការ។ នេះនឹងជួយឱ្យសេវាកម្ម Services Australia ធ្វើឱ្យ ប្រាកដថាអ្នកទទួលបានចំនួនប្រាក់ឧបត្ថម្ភត្រឹមត្រូវនៃប្រាក់ផ្គត់ផ្គង់លើប្រាក់ចំណូល។ ការនេះគឺសំខាន់ ពីព្រោះប្រសិនបើអ្នក ទទួលបានប្រាក់លើសចំនួន អ្នកប្រហែលជាត្រូវបង់សងប្រាក់នេះវិញទៅ Services Australia។

## ចុះប្រសិនបើខ្ញុំមិនយល់ស្របនឹងការសម្រេចដែលបានធ្វើឡើង?

ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសម្រេច ដែលបានធ្វើឡើងដោយ Services Australia ដែលធ្វើឱ្យប៉ះពាល់ដល់ប្រាក់ឧបត្ថម្ភរបស់អ្នក ឬការសម្រេចដែល Services Australia បានធ្វើឡើងអំពី Participation Plan របស់ អ្នក ឬប្រសិនបើអ្នកមានការព្រួយបារម្ភអំពីសេវាកម្មដែលអ្នកបានទទួល សូមទាក់ទងមកខ្សែទូរស័ព្ទទទួលមតិយោបល់ និងបណ្តឹងតវ៉ារបស់ Services Australia ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន លេខ  1800 132 468។

ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីដែលអ្នកផ្តល់សេវាកម្ម ParentsNext របស់អ្នកបានធ្វើឡើងអំពី Participation Plan របស់អ្នក ឬអ្នកមានការព្រួយបារម្ភអំពីសេវាកម្មដែលអ្នកបានទទួល អ្នកអាចពិភាក្សាពីកង្វល់របស់អ្នក ជាមួយអ្នកផ្តល់សេវាកម្មរបស់អ្នក ឬទាក់ទង De-partment of Employment, Skills, Small and Family Business National Customer Service Line តាមទូរស័ព្ទលេខ 1800 805 260 ដែលពួកគេនឹងសើបអង្កេតពីកង្វល់របស់អ្នក។

ប្រសិនបើអ្នកមិនពេញចិត្តនឹងការឆ្លើយតបដែលអ្នកទទួលបាន អ្នកអាចលើកយកបញ្ហានេះបន្ថែមទៀត ដោយទាក់ទង Commonwealth Ombudsman (ការិយាល័យសើបអង្កេតបណ្តឹងតវ៉ាសហព័ន្ធ) តាមទូរស័ព្ទលេខ 1300 362 072។

## សិទ្ធិឯកជន

ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកត្រូវបានការពារដោយច្បាប់ រួមមានច្បាប់ *Privacy Act 1988 (ច្បាប់សិទ្ធិឯកជន ឆ្នាំ១៩៨៨)*។ ព័ត៌មានអាចត្រូវបានគេប្រមូល ប្រើប្រាស់ ឬផ្សព្វផ្សាយនៅកន្លែងដែលអ្នកផ្តល់ការអនុញ្ញាត ឬកន្លែងដែលច្បាប់អនុញ្ញាត។

យើងបានផ្តល់ជូនអ្នកនូវព័ត៌មានស្តីពីសិទ្ធិឯកជនសំខាន់ៗអំពី ការប្រមូល ការប្រើប្រាស់ និងការលាតត្រដាងនូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ ព័ត៌មានបន្ថែមអាចរកបានពី៖

- www.employment.gov.au/privacy
- អ្នកផ្តល់សេវាកម្មរបស់អ្នក
- Services Australia
- Office of the Australian Information Commissioner នៅតាមវ៉ិបសៃថ៍  www.oaic.gov.au

វាជាការសំខាន់ដើម្បីធ្វើឱ្យប្រាកដថា អ្នកបានអាន និងយល់ដឹងពីព័ត៌មាននេះ។